សង្ខេបសម្រាប់
គោលនយោបាយ

CDRI គឺជាវិទ្យាស្ថានកម្ពុជាឯករាជ្យឈានមុខគេ
សម្រាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

ឆ្នាំ ២០១១ លេខ ០៥

# លើកកម្ពស់អភិបាលកិច្ចល្អក្នុងការគ្រប់គ្រងធនធានទឹកនៅកម្ពុជា៖ ការវិភាគអ្នកពាក់ព័ន្ធ[១]

*ដោយ ណាំង ភិរុណ[២] Philip HIRSCH[៣] និង Jessie CONNELL[៤]*

## ខ្លឹមសារសំខាន់ៗ

- មានបញ្ហាលំបាកជាច្រើន ពិសេសផ្នែកអភិបាលកិច្ចធនធានទឹក ដែលអ្នកពាក់ព័ន្ធនានាត្រូវប្រឈមមុខដោះស្រាយ ដើម្បីពង្រឹងការអភិវឌ្ឍ និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្របច្ចុប្បន្ន ។
- គោលនយោបាយគ្រប់គ្រងធនធានទឹកនៅកម្ពុជា ពាក់ព័ន្ធទៅដល់តួអង្គជាច្រើនក្នុងវិស័យសាធារណៈ វិស័យឯកជន និងសហគមន៍មូលដ្ឋាន ដែលមានតួនាទីអនុវត្តការងារគ្រប់គ្រងធនធានទឹក ។ បច្ចុប្បន្ន តួនាទីទាំងនោះពុំទាន់បានកំណត់ច្បាស់លាស់នៅឡើយ ។
- ការដាក់ឲ្យអនុវត្តនូវ គោលនយោបាយគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍ (គធកក) និងការគ្រប់គ្រងធនធានទឹកចម្រុះ (គធទច) បានបង្ហាញនូវការផ្លាស់ប្តូរដ៏ល្អប្រសើរ ឆ្ពោះទៅអនុវត្តការគ្រប់គ្រងធនធានទឹកតាមលក្ខណៈអន្តរជាតិ ដែលមានការចូលរួមយ៉ាងសកម្ម និងប្រកបដោយភាពជាម្ចាស់លើធនធានអំពីសំណាក់សហគមន៍ និងដែលមានការរៀបចំទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធសំខាន់ៗ ឲ្យកាន់តែមានលក្ខណៈល្អប្រសើរត្រឹមត្រូវតាមច្បាប់ ។
- ការអនុវត្តគោលនយោបាយ គធកក និង គធទច នៅកម្ពុជា មិនទាន់អាចដោះស្រាយបានទាំងស្រុងនូវ បញ្ហាសំខាន់ៗ ដែលកើតចេញមកពី ភាពត្រួតស៊ីគ្នានៃតួនាទីអ្នកពាក់ព័ន្ធនៅឡើយ ហើយក៏នៅមានកង្វះខាតមួយចំនួន ដូចជា ការកំណត់ឲ្យបានជាក់លាក់នូវ ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ ការពង្រឹងកិច្ចសហការល្អ និងការចែករំលែកបទពិសោធន៍រវាងអ្នកពាក់ព័ន្ធនានា ក្នុងការគ្រប់គ្រងធារាសាស្ត្រ និងធនធានទឹក ជាដើម ។
- គោលនយោបាយ គធកក បានកំណត់ឲ្យសហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) មានតួនាទី និងសមត្ថកិច្ចសំខាន់ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។ ប៉ុន្តែ សកបទ ភាគច្រើនពុំសូវប្រកាន់យកភាពជាម្ចាស់ លើប្រព័ន្ធធារាសាស្ត្រទេ ។ ពួកគាត់នៅខ្វះខាតបច្ចេកទេស និងជំនាញគ្រប់គ្រងចាំបាច់ ដែលជួយបង្កើនការយល់ដឹងច្បាស់ពីបញ្ហា មុននឹងធ្វើការសម្រេចចិត្តលើការងារបែងចែកទឹក ពិសេសនៅកម្រិតអាងទន្លេ ។
- ការគាំទ្រផ្នែកបច្ចេកទេសជំនាញ គួរតែបង្កើនថែមទៀត ដើម្បីជួយ សកបទ លើការងារគ្រប់គ្រងធារាសាស្ត្រនៅថ្នាក់មូលដ្ឋានក្នុងបរិបទអាងទន្លេ ។
- ការបង្កើតរចនាសម្ព័ន្ធសហការថ្មីមួយ នៅថ្នាក់ក្រោមជាតិ ដើម្បីធ្វើការគ្រប់គ្រងធនធានទឹក និងធារាសាស្ត្រ អាចជួយ

១ អត្ថបទសង្ខេបគោលនយោបាយនេះ ផ្អែកលើឯកសារពិភាក្សាមួយរបស់ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI) ក្រោមប្រធានបទ "ការវិភាគអ្នកពាក់ព័ន្ធ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អក្នុងការគ្រប់គ្រងធនធានទឹកនៅកម្ពុជា" ដោយអ្នកនិពន្ធ ណាំង ភិរុណ ខៀវ ដារ៉ាវី Philip HIRSCH និង Isabelle WHITEHEAD ។ ឯកសារពិភាក្សានេះបង្ហាញពី លទ្ធផលនៃការសិក្សាស្រាវជ្រាវផ្នែកសមាសភាគអភិបាលកិច្ចនៃ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក ដែលជាកម្មវិធីស្រាវជ្រាវមានរយៈពេល ៥ឆ្នាំ ទទួលហិរញ្ញប្បទានពី ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី (AusAID) ដើម្បីជួយកែលម្អការប្រើប្រាស់ និងអភិបាលកិច្ចធនធានទឹក សំដៅលើកកម្ពស់ផលិតភាពកសិកម្ម និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពនៅកម្ពុជា ។

២&៤ លោក ណាំង ភិរុណ និង លោកស្រី Jessie Connell ជាអ្នកស្រាវជ្រាវនៅ វបសអ ក្នុងកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន ។

៣ លោក Philip HIRSCH ជាសាស្ត្រាចារ្យ និងជាអ្នកស្រាវជ្រាវមកពី មជ្ឈមណ្ឌលអូស្ត្រាលីសិក្សាធនធានទន្លេមេគង្គ នៃផ្នែកភូគព្ភសាស្ត្រ នៃសាកលវិទ្យាល័យស៊ីដនី ។

ក្រាហ្វិក ១៖ ទិដ្ឋភាពអ្នកពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន




ប្រភព៖ Pech 2010

បន្ថែមបច្ចេកទេសជំនាញចាំបាច់ដល់ សកបទ និងលើកកម្ពស់ទំនាក់ទំនងរវាង សកបទ អាជ្ញាធរមូលដ្ឋាន និងមន្ទីរជំនាញជុំវិញខេត្ត ឲ្យដំណើរការបានកាន់តែប្រសើរ ។

## បញ្ហាចោទ

ការងារអភិបាលកិច្ចធនធានទឹកនៅកម្ពុជា កំពុងមានការអភិវឌ្ឍរីកចម្រើនគួរឲ្យកត់សំគាល់ ។ ការគ្រប់គ្រងអាងទន្លេសាប និងអាងទន្លេមេគង្គ ស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងចម្រុះ ហើយពាក់ព័ន្ធនឹងសហគមន៍អាងទន្លេ អង្គការសង្គមស៊ីវិល វិស័យឯកជន ទីភ្នាក់ងារផ្តល់ជំនួយ និងស្ថាប័នអភិវឌ្ឍន៍នៃប្រទេសកម្ពុជា និងប្រទេសមួយចំនួនដែលស្ថិតនៅតាមដងទន្លេមេគង្គ ។ ក្រាហ្វិក ១ បង្ហាញពីទិដ្ឋភាពដ៏ស្មុគស្មាញនៃអ្នកពាក់ព័ន្ធទាំងឡាយនៅជុំវិញអាងទន្លេសាប ទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។

ការគ្រប់គ្រងទឹកចម្រុះ ទាមទារកិច្ចសហការល្អក្នុងការអភិវឌ្ឍ និងគ្រប់គ្រងធនធាន ទឹក ដី និងធនធានពាក់ព័ន្ធដទៃទៀត ដើម្បីទទួលបានអត្ថប្រយោជន៍ច្រើនជាអតិបរមាផ្នែកសេដ្ឋកិច្ច និងសង្គម (Global Water Partnership, 2011)[៥] ។ គោលការណ៍នៃ "ការចែករំលែក" ដែលជាសមាសភាគស្នូលនៃ គគទច តម្រូវឲ្យមានការធ្វើវិមជ្ឈការនូវការគ្រប់គ្រងធនធានទឹក ទៅដល់អ្នកអនុវត្តនៅថ្នាក់ក្រោមបំផុត ក្នុងកម្រិតមួយសមស្រប[៦] ។ គោលនយោបាយ គធកក បានឆ្លុះបង្ហាញនូវគោលការណ៍នៃការចែករំលែកនេះ ដែលគេកំពុងដាក់ឲ្យអនុវត្តនៅកម្ពុជា ដើម្បីបង្កើនការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។

៥ GWP 2011. IWRM គឺជាការអភិវឌ្ឍ និងគ្រប់គ្រង ទឹក ដី និងធនធានទាក់ទងផ្សេងទៀត ដើម្បីបង្កើនជាអតិបរមានូវអត្ថប្រយោជន៍ខាងសេដ្ឋកិច្ច និងសង្គម ដោយមិនប៉ះពាល់ដល់និរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ី និងបរិស្ថាន ។

៦ Garfield (1998) បានឲ្យនិយមន័យ "ការចែករំលែក: subsidiarity" ថាជាការផ្ទេរមុខងារជាក់លាក់មួយចំនួន ទៅឲ្យក្រុមនានាក្នុងសហគមន៍មូលដ្ឋាន ដូចជា ការផ្ទេរសិទ្ធិត្រួតត្រាទៅឲ្យអង្គភាពនៅថ្នាក់ក្រោមបំផុត ដើម្បីធ្វើផែនការ និងអនុវត្តកម្មវិធីផ្សព្វផ្សាយបច្ចេកទេសជាដើម (Garfield 1998, cited in WB 2004:2) ។

បច្ចុប្បន្ន គោលនយោបាយ គធកក និង គធទច មិនទាន់បានយកទៅអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នៅឡើយទេ ។ ធនធានទឹកក៏មិនទាន់បានគ្រប់គ្រងក្នុងលក្ខណៈរួមគ្នា ឬតាមបែបវិមជ្ឈការប្រកបដោយប្រសិទ្ធភាពខ្ពស់ដែរ ។ ក្នុងបរិបទធារាសាស្ត្រ មានអ្នកពាក់ព័ន្ធចម្រុះជាច្រើនដែលកំពុងធ្វើការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ដោយផ្អែកតាមទស្សនៈបច្ចេកទេសផ្សេងៗគ្នា ។ ប្រព័ន្ធធារាសាស្ត្រខ្នាតមធ្យម/ធំ អាងស្តុកទឹក និងប្រឡាយមេ ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវដោយផ្ទាល់នៃក្រសួងធនធានទឹក និងឧតុនិយម ។ សកបទ ដែលក្រសួងធនធានទឹក និងឧតុនិយម បានបង្កើតឡើងស្របតាមយុទ្ធសាស្ត្រនៃគោលនយោបាយ គធកក គឺជាអ្នកគ្រប់គ្រងប្រព័ន្ធប្រឡាយរង ហើយជារឿយៗបានផ្ទេរវិមជ្ឈការនូវការគ្រប់គ្រងប្រព័ន្ធប្រឡាយស្រោចស្រពទៅឲ្យ ក្រុមកសិករប្រើប្រាស់ទឹក (កកបទ) ដែលជាផ្នែកមួយស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន (សកបទ) (MOWRAM 1999) ទោះបីជាសមាជិកជាច្រើននៃ កកបទ បានប្រគល់តួនាទីរបស់ខ្លួន ឲ្យទៅប្រធានភូមិជាអ្នកទទួលខុសត្រូវហើយក៏ដោយ ។

## វិធានក្នុងការវិភាគអ្នកពាក់ព័ន្ធ

វិធានក្នុងការវិភាគអ្នកពាក់ព័ន្ធចម្រុះ គឺជាការសិក្សាវិភាគដើម្បីយល់ដឹងឲ្យបានច្បាស់លាស់អំពី តួនាទី ការទទួលខុសត្រូវ ការយល់ដឹង និងទស្សនវិស័យនានារបស់អ្នកពាក់ព័ន្ធតាមរយៈវិធីសាស្ត្រមួយចំនួន ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធចម្រុះនៅកម្រិតផ្សេងៗគ្នា ។ ការវិភាគអ្នកពាក់ព័ន្ធចម្រុះ ធ្វើឡើងតាមវិធីសាស្ត្រមួយដែលក្នុងនោះ ភាពជាក់លាក់ រចនាសម្ព័ន្ធ និងទិដ្ឋភាពឌីណាមិកនៃទំនាក់ទំនងរបស់អ្នកពាក់ព័ន្ធក្នុងវិស័យអភិបាលកិច្ចធនធានទឹក ត្រូវតែយកមកពិនិត្យអង្កេត ដោយផ្តោតជាសំខាន់ទៅលើការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងអាងទន្លេ ។ ទិន្នន័យត្រូវបានប្រមូលតាមរយៈការសាកសួរ និងសម្ភាសអ្នកពាក់ព័ន្ធសំខាន់ៗ អង្កេតដល់ទីកន្លែង និងការប្រជុំពិភាក្សាជាមួយក្រុមគោលដៅ ។ ក្រៅពីនេះ ក៏មានការរៀបចំធ្វើសិក្ខាសាលាថ្នាក់ឃុំ ខេត្ត និងថ្នាក់ជាតិដើម្បីប្រមូល វាយតម្លៃ និងចងក្រងទិន្នន័យ/ព័ត៌មាន ។ ទិន្នន័យទទួលបានតាមរយៈវិធានដូចខាងលើ ត្រូវបានយកទៅប្រើដើម្បីវាយតម្លៃពីអំណាច ផលប្រយោជន៍ និងឥទ្ធិពលនៃក្រុមមនុស្សផ្សេងៗគ្នា ដែលបំពេញការងារពាក់ព័ន្ធនឹងវិស័យធនធានទឹកសម្រាប់កសិកម្ម។

ការស្រាវជ្រាវដល់មូលដ្ឋាន បានធ្វើឡើងលើ ១០ប្រព័ន្ធធារាសាស្ត្រ ក្នុងបីខេត្តនៃប្រទេសកម្ពុជា៖

- ប្រព័ន្ធធារាសាស្ត្របួនក្នុងខេត្តកំពង់ឆ្នាំងគឺមាន ត្រពាំងត្របែក តាំងក្រសាំង ស្វាយចេក និងប៉ក់ប៉ែន
- ប្រព័ន្ធធារាសាស្ត្របីក្នុងខេត្តពោធិ៍សាត់គឺមាន វត្តលៀប កំប៉ាង និងដំណាក់អំពិល
- ប្រព័ន្ធធារាសាស្ត្របីក្នុងខេត្តកំពង់ធំគឺមាន អូរស្វាយ ស្ទឹងជីនិត និងរលួស ។

## លទ្ធផលស្រាវជ្រាវសំខាន់ៗ

បច្ចុប្បន្ន អ្នកពាក់ព័ន្ធទាំងឡាយកំពុងគិតគូររៀបចំឲ្យមានអភិបាលកិច្ចល្អលើធនធានទឹក ដោយផ្តោតការយកចិត្តទុកដាក់ដោះស្រាយតម្រូវការចាំបាច់មួយចំនួន ដើម្បី៖

- បង្កើនការចូលរួមឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងអាងទន្លេ ។
- បកស្រាយពន្យល់ឲ្យកាន់តែច្បាស់លាស់ថា៖ "តើគោលនយោបាយ គធទច/គធកក គួរយកទៅអនុវត្តយ៉ាងដូចម្តេចនៅថ្នាក់មូលដ្ឋាន" និង "តើគោលនយោបាយទាំងនេះមានអន្តរកម្មយ៉ាងដូចម្តេច ជាមួយនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ?" ។
- កែលម្អកិច្ចសហការរវាងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងទូទាំងផ្ទៃអាងរងទឹកភ្លៀង ឬអាងទន្លេ ។
- កំណត់ឲ្យបានជាក់លាក់ពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ និងស្ថាប័នពាក់ព័ន្ធ ។
- បង្កើនប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទង និងដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ថាប័នពាក់ព័ន្ធ ។
- បង្កើនជំនាញបច្ចេកទេសដើម្បីជួយដល់ សកបទ ក្នុងការងារបែងចែកទឹកស្រោចស្រព ។
- ផ្តល់ការគាំទ្រថវិកាក្នុងរយៈពេលវែង និងធ្វើវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ រួមទាំងផ្តល់ការគាំទ្រដល់ដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រផងដែរ ។

## តម្រូវការភាពច្បាស់លាស់អំពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធ

អ្នកពាក់ព័ន្ធមួយចំនួន នៅមានភាពស្រពេចស្រពិលអំពីតួនាទី និងទំហំនៃការទទួលខុសត្រូវរបស់ក្រសួង និងគណៈកម្មាធិការនានា ព្រមទាំងនីតិវិធីចាំបាច់ដើម្បីធ្វើឲ្យស្ថាប័នពាក់ព័ន្ធទាំងនោះ មានទំនាក់ទំនងការងារគ្នាពីមួយទៅមួយ ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន ។ ការស្រាវជ្រាវបង្ហាញថា ដើម្បីឲ្យគោលនយោបាយ គធកក អាចអនុវត្តបានប្រកបដោយប្រសិទ្ធភាពខ្ពស់ ត្រូវកំណត់ឲ្យបានច្បាស់ និងមិនត្រួតស៊ីគ្នានូវការទទួលខុសត្រូវ (ក្នុងវិស័យធនធានទឹក) របស់ស្ថាប័នពាក់ព័ន្ធនីមួយៗ ដូចជា ស្ថាប័នរដ្ឋាភិបាលពិសេសក្រសួង/មន្ទីរធនធានទឹក និងឧតុនិយម អ្នកផ្តល់ជំនួយ រដ្ឋអំណាចមូលដ្ឋាន សកបទ និងកសិករ ជាដើម ។

## តម្រូវការជំនួយបច្ចេកទេសបន្ថែម

អ្នកពាក់ព័ន្ធ ចង់ឲ្យមានការជួយគាំទ្រផ្នែកបច្ចេកទេសបន្ថែម និងការបកស្រាយពន្យល់ឲ្យបានកាន់តែច្បាស់ពីតួនាទី និងលក្ខណៈនៃការគ្រប់គ្រងទឹកចម្រុះ ព្រមទាំងទំនាក់ទំនងនឹងគោលនយោបាយដទៃទៀត ដូចជា គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងគោលនយោបាយ គធកក ជាដើម ។ ការស្រាវជ្រាវនៅថ្នាក់ភូមិបានបង្ហាញនូវគំលាតរវាងអាណត្តិតាមច្បាប់ដែល សកបទ បានទទួល ហើយនិងប្រសិទ្ធភាពពិតប្រាកដរបស់អាណត្តិនោះ ។ សកបទ នៅតាមតំបន់មួយចំនួនពុំមានជំនាញគ្រប់គ្រាន់ និងព័ត៌មានចាំបាច់ ដើម្បីធ្វើការសម្រេចចិត្តលើការបែងចែកទឹកនៅកម្រិតប្រព័ន្ធធារាសាស្ត្រនោះទេ ។ ទោះបីជា សកបទ មានការទទួលខុសត្រូវតាមផ្លូវច្បាប់ និងតាមបែបបទរដ្ឋបាល ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រក្តី ក៏កសិករភាគច្រើនមិនបានបង្ហាញស្មារតីជាម្ចាស់លើប្រព័ន្ធធារាសាស្ត្រ ឬគម្រោងធារាសាស្ត្រទេ គឺពួកគាត់នៅតែបន្តស្នើសុំជំនួយឧបត្ថម្ភពីរដ្ឋអំណាចមូលដ្ឋាន និងមន្ទីរធនធានទឹក និងឧតុនិយម ដើម្បីដោះស្រាយបញ្ហានានាដែលកើតចេញពីការប្រើប្រាស់ទឹក ។ ក្នុងពេលសម្ភាសន៍នៅតាម បណ្តាប្រព័ន្ធធារាសាស្ត្រដែលបានចុះសិក្សា កសិករបានឆ្លើយប្រាប់ថា នៅដំណាក់កាលដំបូងនៃការបង្កើតក្រុមកសិករប្រើប្រាស់ទឹក (កកបទ) តួនាទីរបស់សមាជិកក្រុមនីមួយៗមានកំណត់ច្បាស់លាស់ណាស់ ។ ប៉ុន្តែបន្ទាប់មកទៀត ដោយសារបញ្ហាចោទក្នុងជីវភាពរស់នៅ កង្វះជំនាញ និងកង្វះកិច្ចសហការល្អរវាងសមាជិក កកបទ និងកសិករ បណ្តាលឲ្យសមាជិក កកបទ មួយចំនួនបានបោះបង់ចោលតួនាទីរបស់ខ្លួន ហើយនេះជាមូលហេតុដែល កកបទ ភាគច្រើន សព្វថ្ងៃកំពុងស្ថិតក្រោមការដឹកនាំរបស់ប្រធានភូមិ ។

## ការលើកកម្ពស់ភាពពេញច្បាប់របស់ សកបទ

ដោយសារប្រព័ន្ធធារាសាស្ត្រភាគច្រើន ពុំមានប្រព័ន្ធប្រឡាយស្រោចស្រពគ្រប់គ្រាន់ ដូច្នេះ សកបទ ជួបការលំបាកក្នុងការប្រមូលថ្លៃសេវាកម្មប្រើប្រាស់ទឹកចាំបាច់ សម្រាប់យកមកដំណើរការ និងថែទាំប្រព័ន្ធធារាសាស្ត្រ ។ កង្វះស្មារតីជាម្ចាស់របស់សហគមន៍មូលដ្ឋានលើប្រព័ន្ធធារាសាស្ត្រ កើតឡើងមួយផ្នែកដោយសារកង្វះភាពពេញច្បាប់នៃ សកបទ ដែលបង្កឡើងដោយការលំបាក និងភាពយឺតយ៉ាវក្នុងដំណើរការចុះបញ្ជីទទួលស្គាល់ សកបទ ជាផ្លូវការ ។ ម៉្យាងទៀត ទោះបីសកបទ បានក្លាយជាស្ថាប័នឯករាជ្យមានអាណត្តិច្បាស់លាស់ក្នុងកិច្ចសហការ និងសម្របសម្រួលរាល់បញ្ហាពាក់ព័ន្ធនឹងទឹកក៏ដោយ ក៏ការខ្វះខាតអំណាចគ្រប់គ្រាន់សម្រាប់ដោះស្រាយបញ្ហា បានបង្កការលំបាកដល់ សកបទ ក្នុងការដោះស្រាយ និងគ្រប់គ្រងទំនាស់ ។ ដោយមូលហេតុនេះ ក្នុងការអនុវត្តជាក់ស្តែងនូវតួនាទីស្នូលរបស់ខ្លួន សកបទ ត្រូវតែពឹងផ្អែកលើរដ្ឋអំណាចមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល និងអង្គការអន្តរជាតិដទៃទៀត ។

## តម្រូវការពង្រឹងទំនាក់ទំនង និងកិច្ចសហការរវាងអ្នកពាក់ព័ន្ធ

ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធជនបទនៅកម្ពុជា បានកសាងឡើងដោយប្រើថវិការបស់រាជរដ្ឋាភិបាល រួមនឹងស្ថាប័នផ្តល់ជំនួយអន្តរជាតិ និងដោយមានការចូលរួមរបស់ប្រជាពលរដ្ឋដែលជាអ្នកទទួលផលប្រយោជន៍ពីគម្រោង តាមរយៈការបរិច្ចាគដីធ្លី និងកម្លាំងពលកម្ម ។ ប្រព័ន្ធអភិបាលកិច្ចធនធានទឹកបច្ចុប្បន្ន កំពុងប្រឈមនឹងបញ្ហាកង្វះយន្តការឆ្លើយតបសមស្រប និងកិច្ចសហការគ្នាល្អរវាងស្ថាប័នរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធជាតិ/អន្តរជាតិនៅកម្រិតផ្សេងៗគ្នា ។ នៅកម្រិតអាងទន្លេ/ស្ទឹង ពុំមានវេទិកាប្រកបដោយប្រសិទ្ធភាពសម្រាប់ សកបទ ធ្វើការពិភាក្សារួមគ្នាអំពីបញ្ហាធារាសាស្ត្រនៅឡើយ ។ ដូច្នេះគួររៀបចំឲ្យមានយន្តការអភិបាលកិច្ចតាមរយៈខ្សែបណ្តោយ ឬខ្សែទទឹង សម្រាប់ធ្វើទំនាក់ទំនងជាមួយស្ថាប័នរដ្ឋាភិបាលថ្នាក់កណ្តាល (ក្រសួង) ថ្នាក់ខេត្ត អាជ្ញាធរមូលដ្ឋាន និងថ្នាក់ភូមិ ។ ជាពិសេស គួរពង្រឹងយន្តការអភិបាលកិច្ចតាមខ្សែបណ្តោយ ដើម្បីសម្របសម្រួលការចែករំលែកព័ត៌មាន និងជំនាញ រវាងមន្ទីរជំនាញរបស់រដ្ឋាភិបាល អាជ្ញាធរឃុំ/សង្កាត់ ប្រធានភូមិ អ្នកពាក់ព័ន្ធជាតិ/អន្តរជាតិ និងសាកលវិទ្យាល័យផ្សេងៗ ។

រដ្ឋាភិបាលបានបង្កើត ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក (កបកទ) ដើម្បីលើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពនៃកិច្ចសហការរវាងអ្នកពាក់ព័ន្ធនានា ជាមួយនឹងស្ថាប័នរដ្ឋាភិបាល ជាពិសេសរវាងក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាស្ថាប័នដឹកនាំការអនុវត្តកម្មវិធីអភិវឌ្ឍន៍ ក្រោមផែនការយុទ្ធសាស្ត្រកសិកម្ម និងទឹក (SAW 2007)។ កន្លងមក កបកទ បានសហការ និងជួយសម្រួលការងារបច្ចេកទេសយ៉ាងសកម្មជាមួយបណ្តាស្ថាប័នពាក់ព័ន្ធ សហគមន៍ អ្នកផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ។ កបកទ គឺជាវេទិកាដ៏មានសក្តានុពលសម្រាប់នាំយកជំនួយបច្ចេកទេស ទៅជួយដល់បណ្តាសហគមន៍មូលដ្ឋាន ជាពិសេស សកបទ ។

## ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ

នៅក្នុងតំបន់ដែលប្រព័ន្ធធារាសាស្ត្រ មិនទាន់បានសាងសង់គ្រប់គ្រាន់ សហគមន៍ពិបាកនឹងចូលរួមឲ្យបានសកម្មណាស់ ។ ប្រសិនបើប្រព័ន្ធធារាសាស្ត្រ មិនអាចផ្តល់អត្ថប្រយោជន៍ទាន់ពេលដល់កសិករទេ ប្រព័ន្ធនោះពិតជាមានចំណុចខ្វះខាតផ្នែកបច្ចេកទេស ធ្វើឲ្យកសិករជួបការលំបាកក្នុងការរកចំណូលថវិកា និងមិនចង់ចូលរួមសហការក្នុងការថែទាំវា ។ នៅថ្នាក់

មូលដ្ឋាន ការចូលរួមរបស់កសិករ និង សកបទ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ គឺអាស្រ័យទៅលើដំណើរការប្រកបដោយប្រសិទ្ធភាព និងភាពគួរឲ្យជឿទុកចិត្តបាននៃប្រព័ន្ធនោះ ។

## លទ្ធផលរកឃើញជាគន្លឹះសំខាន់ សម្រាប់ការរៀបចំគោលនយោបាយគ្រប់គ្រងធនធានទឹក[៧]

ការសិក្សានេះ បានស្នើដល់អ្នកពាក់ព័ន្ធឲ្យលើកឡើងនូវគោលការណ៍នៃដំណោះស្រាយ ផ្អែកតាមការអនុវត្តជាក់ស្តែង សម្រាប់យកទៅដោះស្រាយបញ្ហាប្រឈមនានា ដែលត្រូវជួបប្រទះក្នុងការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។ គោលការណ៍ទាំងនោះ ត្រូវបានលើកយកមកពិភាក្សាសម្រិតសម្រាំងបន្ថែម នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់សហគមន៍ បន្ទាប់មកជាក់ឆ្លង សិក្ខាសាលាថ្នាក់ខេត្តជាបន្តបន្ទាប់ទៀត ដោយមានការចូលរួមពីសំណាក់ សកបទ និងអ្នកតំណាងមកពីមន្ទីរធនធានទឹក និងឧតុនិយមនៃខេត្តទាំងបីខាងលើ ។ គោលការណ៍ទាំងនោះ មានជាអាទិ៍៖

១. គួរបង្កើតអនុគណៈកម្មាធិការគ្រប់គ្រងធារាសាស្ត្រ និងអាងទន្លេ (អគធអ)[៨] នៅថ្នាក់ក្រោមជាតិ ដើម្បី៖

- សហការជាមួយ សកបទ មន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត និងអាជ្ញាធរមូលដ្ឋាន និងជួយផ្តល់ចំណេះដឹង ជំនាញ និងយោបល់សព្វបែបយ៉ាង ដល់មន្ទីរពាក់ព័ន្ធជុំវិញខេត្ត អង្គការមិនមែនរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងអ្នកជំនាញការអន្តរជាតិនៅក្នុងការងារជលសាស្ត្រ និងការគ្រប់គ្រងទឹកចម្រុះ ។
- បណ្តុះការយល់ដឹងទូទៅ ក្នុងចំណោមអ្នកពាក់ព័ន្ធអំពីគោលនយោបាយ គធទច និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក៏ដូចជាគាំទ្រដល់ការធ្វើសមាហរណកម្មនៃបណ្តាសហគមន៍នៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម។
- លើកកម្ពស់ដំណើរការ "ពីក្រោមទៅលើ" សម្រាប់ប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងមធ្យម ។

- ផ្តល់ជាវេទិកា ដើម្បីរៀបចំអង្គាសថវិកាសម្រាប់កិច្ចដំណើរការ និងថែទាំប្រព័ន្ធ ។
- ជួយដោះស្រាយទំនាស់ និងបង្កលក្ខណៈឲ្យ សកបទ និងកសិកររួមសហការគ្នាធ្វើផែនការដាំដុះ និងប្រមូលផលតាមរយៈចំណេះដឹងផ្នែកជលសាស្ត្រ កសិកម្ម និងសង្គម ។

## បញ្ហាគួរពិនិត្យពិចារណា

- តើស្ថាប័នណាគួរដឹកនាំ ឬគ្រប់គ្រងអនុគណៈកម្មាធិការនេះ? តើអនុគណៈកម្មាធិការនេះ គួរស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នថ្នាក់ខេត្ត ឬថ្នាក់អាងទន្លេ?
- តើអនុគណៈកម្មាធិការនេះ គួរមានអាណត្តិពេញលេញដើម្បីធ្វើសេចក្តីសម្រេចចិត្ត ឬក៏មានតួនាទីត្រឹមតែផ្តល់ការប្រឹក្សា?
- អនុគណៈកម្មាធិការនេះ អាចមានទម្រង់ខុសៗគ្នាពីតំបន់មួយទៅតំបន់មួយ អាស្រ័យដោយលក្ខណៈធម្មជាតិនៃអាងទន្លេ និងកម្រិតសមត្ថភាពរបស់អ្នកពាក់ព័ន្ធនៅទីនោះ ។
- គួរមានការពិគ្រោះយោបល់បន្ថែម ជាមួយនឹងអ្នកពាក់ព័ន្ធសំខាន់ៗជាមុនសិន មុននឹងបង្កើតអនុគណៈកម្មាធិការនេះឡើង ។

២. ផ្តល់ការអប់រំបណ្តុះបណ្តាលដល់ អ្នកពាក់ព័ន្ធនៅមូលដ្ឋាន ពិសេសមន្ត្រីមន្ទីរធនធានទឹក និងឧតុនិយម ក្រុមប្រឹក្សាឃុំ/សង្កាត់ កសិករ និងសមាជិកគណៈកម្មាធិការ សកបទ អំពីសិទ្ធិ និងកាតព្វកិច្ច ក្នុងការគ្រប់គ្រងធនធានធម្មជាតិ៖ វគ្គបណ្តុះបណ្តាលគួរផ្តោតលើប្រធានបទដូចខាងក្រោម៖

- ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ព្រៃឈើ ជលផល ដី និងបរិស្ថាន
- គោលនយោបាយស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និង គធកក
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល[៩] (Organic Law)
- គោលការណ៍ណែនាំ និងបទដ្ឋាននានានៃច្បាប់រដ្ឋបាល ។

៣. ពង្រឹងសមត្ថភាពគណៈកម្មាធិការ សកបទ និង ក្រុមប្រឹក្សាឃុំ/សង្កាត់ លើមុខជំនាញផ្នែក៖

- ដឹកនាំ សម្របសម្រួល និងទំនាក់ទំនង
- បែងចែកថវិកា និងគ្រប់គ្រងហិរញ្ញវត្ថុ
- គ្រប់គ្រងធនធានធម្មជាតិ ប្រព័ន្ធធារាសាស្ត្រ កសិកម្ម និងដំណាំដាំដុះ
- គ្រប់គ្រង និងអភិវឌ្ឍគម្រោង ។

៤. លើកកម្ពស់គណនេយ្យភាពរបស់ សកបទ និងក្រុមប្រឹក្សាឃុំ/សង្កាត់ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បី៖

---

៧ សំរាប់ព័ត៌មានបន្ថែមសូមអានឯកសារពិភាក្សាដែល វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ផិតចេញផ្សាយក្រោមប្រធានបទ "ការវិភាគអ្នកពាក់ព័ន្ធ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អក្នុងការគ្រប់គ្រងធនធានទឹកនៅកម្ពុជា" ដោយអ្នកនិពន្ធ ណាំង ភិរុណ ខៀវ ដាំ៉វី Philip HIRSCH និង Isabelle WHITEHEAD ។

៨ ផ្អែកលើមូលដ្ឋាននៃការឆ្លើយតបរបស់អ្នកពាក់ព័ន្ធ អគធអ អាចដំណើរការជា "មជ្ឈមណ្ឌលសេវាកម្ម" សម្រាប់គាំទ្រដល់ សកបទ និងអ្នកពាក់ព័ន្ធឯទៀត ដើម្បីគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាពក្នុងបរិបទសង្គម និងបរិស្ថានមួយដ៏ទូលាយ ហើយក៏អាចដំណើរការប្រហែលគ្នានឹងអង្គការគ្រប់គ្រងអាងទន្លេ (RBO) ដើម្បីដោះស្រាយទំនាស់ និងបង្កើនកិច្ចសហការ ។ ការបង្កើតអនុគណៈកម្មាធិការនេះ ក៏ដើម្បីរៀនសូត្រពីបទពិសោធន៍ និងការគាំទ្រកន្លងមក ដោយមិនបង្កឲ្យមានភាពត្រួតស៊ីគ្នាដល់ការរៀបចំ និងរចនាសម្ព័ន្ធគ្រប់គ្រងដែលមានស្រាប់ ។

៩ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨
🖷 (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

- ពង្រីកការផ្តល់ផលប្រយោជន៍ពីប្រព័ន្ធធារាសាស្រ្ត ដល់កសិករ ដោយវិះរកបច្ចេកទេសធារាសាស្រ្តសមស្របថ្មីៗ ដើម្បីបែងចែក និងគ្រប់គ្រងទឹក និងបច្ចេកទេសកសិកម្មប្រពលវប្បកម្មដែលផ្តល់ទិន្នផលខ្ពស់ ។
- ផ្តល់ទឹកសម្រាប់ស្រោចស្រព និងព័ត៌មានកសិកម្មទាន់ពេលវេលា និងជម្រុញកសិករឲ្យចូលរួមការពារផលប្រយោជន៍សាធារណៈ ។

៥. ពង្រីកកិច្ចសហការរវាងអ្នកពាក់ព័ន្ធនៅតំបន់ជុំវិញបឹងទន្លេសាបឲ្យកាន់តែល្អប្រសើរ

- ចែករំលែកការយល់ដឹងអំពី គោលការណ៍កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និង គធកក ដល់អ្នកពាក់ព័ន្ធទាំងអស់
- ចែករំលែកថវិកាសមស្រប សម្រាប់ដំណើរការបែងចែក និងគ្រប់គ្រងទឹក និងសម្រាប់កិច្ចការរដ្ឋបាលដើម្បីគាំទ្រដល់ការងាររបស់ សកបទ
- ក្នុងករណីដែល អគធអ មិនទាន់បានបង្កើតឡើង គួររៀបចំឲ្យមានយន្តការចាំបាច់ ដើម្បីបង្កើនកិច្ចសហការល្អរវាងសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល វិស័យឯកជន និងមន្ទីរពាក់ព័ន្ធជុំវិញខេត្ត ដើម្បីកំណត់អាទិភាពនៃបញ្ហាធារាសាស្រ្ត និងបញ្ហាបន្ទាន់ផ្សេងៗ ។

## ប្រធានបទសម្រាប់សិក្សាស្រាវជ្រាវបន្ថែម

ករណីសិក្សា និងសិក្ខាសាលាថ្នាក់ខេត្ត ដែលបានធ្វើឡើងនៅខេត្តទាំងបី បានបង្ហាញថា ការបញ្ចូលសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ទៅក្នុងរចនាសម្ព័ន្ធ សកបទ (ជាសមាជិកគណៈកម្មាធិការ សកបទ) អាចជួយលើកកម្ពស់ប្រតិបត្តិការរបស់ សកបទ ឲ្យមានដំណើរការល្អ ។ ដូច្នេះ ការស្រាវជ្រាវបន្ទាប់ គួរផ្តោតលើប្រធានបទ៖ "តើគួរបញ្ចូលសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃគណៈកម្មាធិការ សកបទ ដើម្បីជួយគាំទ្រផ្នែកបច្ចេកទេស និងសមត្ថកិច្ចដែរឬទេ?"

## ឯកសារយោង

CDRI (2011), *Improving the Governance of Water Resources in Cambodia: A Stakeholder Analysis*, by Nang Phirun, Khiev Daravy, Philip Hirsch & Isabelle Whitehead, CDRI Working Paper (forthcoming) (Phnom Penh, Cambodia: CDRI)

Global Water Partnership (2011), *What is IWRM?* http://www.gwp.org/en/The-Challenge/What-is-IWRM/ (accessed 28 December 2010)

MOWRAM (1999), *Implementation Policy of Sustainable Irrigation Systems*, Circular No. 1, dated 11 January 1999 (Phnom Penh, Cambodia: RGC)

Pech S. (2010), "Cambodian and Mekong Water Resources Governance", in J. Sato (ed.) *Transboundary Resources and Environment in Mainland Southeast Asia*, Institute for Advanced Studies on Asia, the University of Tokyo

Royal Government of Cambodia, (2008), Law No. NS/RKM/0508/017 dated May 2008 on "Administrative Management of the Capital, Provinces, Municipalities, Districts and Khans", (Phnom Penh: RGC) http://www.ncdd.gov.kh/legal-framework/law (accessed on June 7, 2011)

TWGWA (2007), *Strategy on Agriculture and Water 2007* (Phnom Penh, Cambodia: RGC)

World Bank (2004), Volume 1, Decentralised Systems: *Case Studies of International Initiatives* (Washington,DC: World Bank) http://www.g-fras.org/fileadmin/UserFiles/Documents/Case-studies/Decentralized-Systems.pdf (accessed 29 December 2010)